## ស្ថងការនៃកិច្ចបំរើខាងសុខភាពអាចជួយលោកអ្នកដោះស្រាយនឹងបញ្ហានានាស្តីពី ៖

- ការថែទាំមិនបានពេញចិត្ត
- ការសម្ងាត់នៃ- និង-ឬសិទ្ធិរកពត៌មានសុខភាពស្តីពីលោកអ្នក
- បញ្ហានៃការទាក់ទងគ្នា
- ខ្វះសេចក្តីគោរព, សេចក្តីថ្លៃថ្នូរ ឬការសម្ងាត់
- ឥរិយាបថធ្វេសប្រហែស ឬមិនសមរម្យជាអ្នកមានវិជ្ជាជីវ:

### ទូរស័ព្ទមកយើង ហើយយើងនឹង ៖

- ស្តាប់
- ផ្តល់លោកអ្នកនូវពត៌មាន និង ឱវាទ
- ជួយលោកអ្នករកចម្លើយនៃសំណួររបស់លោកអ្នក ។
- សម្រុះសម្រួលជាផ្លូវការឬក្រៅផ្លូវការរវាងភាគីទាំងអស់ ។

## យើងអាចជួយលោកអ្នកដោះស្រាយបញ្ហានានាដែលទាក់ទិននឹង ៖

### ១-អ្នកផ្តល់កិច្ចបំរើខាងសុខភាពដែលមាន ៖

- វេជ្ជបណ្ឌិត
- ពេទ្យធ្មេញ
- អ្នកឲ្យឱវាទ
- គិលានុបដ្ឋាយិកា
- អ្នកឯកទេស
- ឱសថការី
- រថយន្តពេទ្យ
- អ្នកព្យាបាលរោគដោយវិធីធម្មជាតិ
- មន្ទីរពេទ្យសាធារណ: និងឯកជន
- កិច្ចបំរើខាងសុខភាពសហគមន៍

ហើយនិងអ្នកដ៏ទៃទៀតដែលផ្តល់កិច្ចបំរើខាងសុខភាព ។

### ២-ការសម្ងាត់នៃពត៌មានសុខភាពរបស់លោកអ្នកដែលរក្សាទុកដោយជនណាម្នាក់ ឬអង្គការណាមួយក្នុងរដ្ឋវិចតូរិយ៉ាដែលមាន ៖

- អ្នកផ្តល់កិច្ចបំរើខាងសុខភាព
- មជ្ឈមណ្ឌលហាត់ប្រាណឲ្យមានសុខភាពល្អ
- សាលារៀន
- មត្តេយ្យសាលា
- និយោជក
- ទីភ្នាក់ងាររដ្ឋាភិបាល

## តើធ្វើអ្វីខ្លះ ប្រសិនបើលោកអ្នកមានបទបណ្តឹងណាមួយ

ជំហានទីមួយរបស់លោកអ្នកគឺទាក់ទងនឹងជននោះ ឬអង្គការនោះហើយសាកល្បងដោះស្រាយបញ្ហានោះជាមួយគេ ។

ប្រសិនបើលោកអ្នកយល់ថាជាការលំបាក ឬក៏នៅមិនសប្បាយចិត្តទៀត, ដូច្នេះសូមទូរស័ព្ទមកយើង ។

### តើជនណាផ្សេងទៀតដែលការពារការសម្ងាត់?

ការិយាល័យស្នងការរក្សាការសម្ងាត់រដ្ឋវិចតូរិយ៉ាត្រួតមើលរបៀបដែលទីភ្នាក់ងាររដ្ឋាភិបាលរដ្ឋវិចតូរិយ៉ាហើយនិងសាលាសង្កាត់នៃតំបន់នានា ប្រមូលផ្តុំហើយនិងចាត់ចែងពត៌មានផ្ទាល់ខ្លួន ក្រៅពីពត៌មានខាងសុខភាព ។

**ទូរស័ព្ទ ៖ ១៣០០ ៦៦៦ ៨៨៨**

ស្នងការខាងការសម្ងាត់សហព័ន្ធត្រួតមើលទីភ្នាក់ងាររដ្ឋាភិបាលសហព័ន្ធ ដូចជា សិនធីលិង (Centrelink) និងការិយាល័យពន្ធដារ (Tax Office) ហើយនិងផ្នែកឯកជនជាច្រើនទៀត ដែលមានទាំងអ្នកផ្តល់កិច្ចបំរើខាងសុខភាពឯកជនផងដែរ ។

**ទូរស័ព្ទ ៖ ១៣០០ ៣៦៣ ៩៩២**



## ស្តង់ការនៃកិច្ចបំរើខាងសុខភាព(HSC)

ការិយាល័យស្តង់ការនៃកិច្ចបំរើខាងសុខភាពគឺជាអាជ្ញាធរពេញច្បាប់មួយឯករាជ្យ, មិនលំអៀង ដែលបានបង្កើតឡើងដោយក្រិត្យនៃកិច្ចបំរើខាងសុខភាព នាឆ្នាំ ១៩៨៧ (ការសម្រុះសម្រួល ហើយនិង ការពិនិត្យឡើងវិញ) ។

(HSC) ក៏មានការទទួលខុសត្រូវខាងការចាត់ចែង ក្រិត្យរក្សាឯកសារខាងសុខភាព នាឆ្នាំ២០០១ ។ ក្រិត្យនេះបានធ្វើឲ្យមានក្បួនខ្នាត ចំពោះ ការប្រមូលផ្តុំ, ការប្រើប្រាស់, ការបញ្ចេញឲ្យដឹង, គុណភាព, សន្តិសុខ, សិទ្ធិរក, ការរក្សាទុក ហើយនិងការផ្ទេរពត៌មានខាងសុខភាព ។

- (HSC) ការពារសិទ្ធិរបស់លោកអ្នកក្នុងការរកពត៌មានសុខភាពរបស់លោកអ្នក
- យើងអាចជួយលោកអ្នករកចម្លើយនៃកង្វល់របស់លោកអ្នកនឹងកិច្ចបំរើខាងសុខភាព
- កិច្ចបំរើយើងគឺឥតគិតថ្លៃឡើយ ហើយរក្សាការសម្ងាត់ទៀតផង

## ពត៌មានបន្ថែមទៀត


**Office of the Health Services Commissioner**
**ការិយាល័យស្តង់ការនៃកិច្ចបំរើខាងសុខភាព**

ជាន់ទី 30

570 Bourke Street

Melbourne 3000

វែបសៃត៍: www.health.vic.gov.au/hsc

អ៊ីម៉ែល: hsc@dhs.vic.gov.au

ទូរស័ព្ទ: (03) 8601 5200

ទូរស័ព្ទឥតគិតថ្លៃ: 1800 136 066

ហ្វែក: (03) 8601 5219

TTY: 1300 550 275

DX: 210182


Edition 1-April 2002

# តើមានបញ្ហាជាមួយនឹងកិច្ចបំរើខាងសុខភាព ឬមានកង្វល់នឹងការសម្ងាត់នៃសុខភាព របស់លោកអ្នកឬទេ?

## យើងអាចជួយបាន

Cambodian

## ការិយាល័យស្តង់ការនៃកិច្ចបំរើខាងសុខភាព

